ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ.៥២០.....សហវ.ប្រក

# ប្រកាស
## ស្តីពី
## ការបង្កើតក្រុមការងាររៀបចំផែនការយុទ្ធសាស្ត្រថវិកា និងកញ្ចប់ថវិកាប្រចាំឆ្នាំ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញ អនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ១.-**

ត្រូវបានបង្កើតក្រុមការងាររៀបចំផែនការយុទ្ធសាស្ត្រថវិកានិងកញ្ចប់ថវិកាប្រចាំឆ្នាំ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលសរសេរជាអក្សរកាត់ថា “**គ.ផ.គ.**”។


ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St. 92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone: 855-23-724 664 Fax : 855-23-427 798

**ប្រការ២.-**

**គ.ផ.គ.** មានសមាសភាពដូចតទៅ÷

១. រដ្ឋលេខាធិការ ទទួលបន្ទុក ០១ រូប ប្រធាន
២. អគ្គលេខាធិការ ទទួលបន្ទុក អនុប្រធាន
៣. អគ្គលេខាធិការ នៃគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ សមាជិក
៤. អគ្គនាយក នៃអគ្គនាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈ សមាជិក
៥. អគ្គនាយក នៃអគ្គនាយកដ្ឋានថវិកា សមាជិក
៦. អគ្គនាយក នៃអគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ សមាជិក
៧. អគ្គនាយក នៃអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ សមាជិក
៨. អគ្គនាយក នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា សមាជិក
៩. អគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ សមាជិក
១០. អគ្គនាយក នៃអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ សមាជិក
១១. អគ្គនាយក នៃអគ្គនាយកដ្ឋានរតនាគារជាតិ សមាជិក
១២. អគ្គនាយក នៃអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ សមាជិក
១៣. អគ្គាធិការ នៃអគ្គាធិការដ្ឋាន សមាជិក
១៤. អគ្គនាយក នៃអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង សមាជិក
១៥. អគ្គនាយក នៃគណៈកម្មការមូលបត្រកម្ពុជា សមាជិក
១៦. តំណាងក្រុមប្រឹក្សាជាតិគណនេយ្យ សមាជិក។

សមាសភាពជាក់ស្តែងនៃ **គ.ផ.គ.** ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**ប្រការ៣.-**

**គ.ផ.គ.** មានមុខងារនិងភារកិច្ចដូចខាងក្រោម÷

- ពិនិត្យ ផ្តល់ការណែនាំ និងកែលម្អលើការរៀបចំផែនការយុទ្ធសាស្ត្រថវិកានិងកញ្ចប់ថវិកាប្រចាំឆ្នាំរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- រៀបចំនិងលើកសំណើអំពីគោលនយោបាយ កម្មវិធី និងអនុកម្មវិធីរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជូនថ្នាក់ដឹកនាំក្រសួង
- ពិនិត្យនិងកែលម្អសកម្មភាពនិងសូចនាករសមិទ្ធកម្មគន្លឹះ ឱ្យឆ្លើយតបតាមការកំណត់គោលបំណងគោលនយោបាយ កម្មវិធី និងអនុកម្មវិធីរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ធានាសង្គតិភាព បូរណភាព និងភាពទាន់ពេលវេលា នៃការរៀបចំផែនការយុទ្ធសាស្ត្រថវិកានិងកញ្ចប់ថវិកាប្រចាំឆ្នាំរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជូនថ្នាក់ដឹកនាំក្រសួង
- ត្រួតពិនិត្យនិងវាយតម្លៃ លើសមិទ្ធកម្មនៃការអនុវត្តថវិកាប្រចាំឆ្នាំ ដើម្បីកែលម្អផែនការយុទ្ធសាស្ត្រថវិកានៅឆ្នាំបន្ទាប់។

**ប្រការ៤.-**

**គ.ផ.គ.** មានក្រុមការងារបច្ចេកទេសមួយជាសេនាធិការ ដើម្បីបំពេញមុខងារនិងភារកិច្ចរបស់ខ្លួន។

ក្រុមការងារបច្ចេកទេសនេះ ត្រូវបង្កើតឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**ប្រការ៥.-**

សមាសភាពនៃ **គ.ផ.គ.** ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។

ក្នុងករណីប្រធានអវត្តមាន អនុប្រធានត្រូវអញ្ជើញនិងដឹកនាំការប្រជុំជំនួស។

**គ.ផ.គ.** មានសិទ្ធិអញ្ជើញមន្ត្រីពាក់ព័ន្ធផ្សេងទៀត នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ចូលរួមប្រជុំតាមការចាំបាច់។

**ប្រការ៦.-**

ប្រកាសលេខ ៤៩៥ សហវ.ប្រក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១០ ស្តីពីការបង្កើតក្រុមការងាររៀបចំផែនការយុទ្ធសាស្ត្រថវិការបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៧.-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន និងប្រធានអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១៤

**រដ្ឋមន្ត្រី**

**ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល÷**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម/លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ក្រសួងមុខងារសាធារណៈ
- សាលារាជធានី ខេត្ត
- ដូចប្រការ៧
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ